អាជ្ញាធរមីន

C.M.A.A

ប្រព័ន្ធព័ត៌មានជនរងគ្រោះដោយសារមីន និងសំណល់ជាតិផ្ទុះពីសង្គ្រាម

# របាយការណ៍
# ប្រចាំ
# ខែមិថុនា ឆ្នាំ ២០១៩

## សាវតារ

ប្រព័ន្ធព័ត៌មានជនរងគ្រោះដោយសារមីន និងសំណល់ជាតិផ្ទុះពីសង្គ្រាម (CMVIS) ត្រូវបានបង្កើតឡើងនៅឆ្នាំ១៩៩៤ ដោយកាកបាទក្រហមកម្ពុជា ដោយមានការគាំទ្រថវិកា និងបច្ចេកទេសពីអង្គការជនពិការអន្តរជាតិបែលហ្សិក និងអង្គការយូនីសេហ្វ ក្នុងការផ្តល់នូវការប្រមូលទិន្នន័យ វិភាគទិន្នន័យ បកស្រាយទិន្នន័យ និងការចែកចាយទិន្នន័យជនរងគ្រោះដោយសារមីន និងសំណល់ជាតិផ្ទុះពីសង្គ្រាម(ស.ផ.ស.) ជាជនស៊ីវិល និងយោធា នៅក្នុងប្រទេសកម្ពុជា។

នៅដំណាច់ឆ្នាំ២០០៩ CMVIS ត្រូវបានផ្ទេរប្រគល់ពីកាកបាទក្រហមកម្ពុជា មកស្ថិតនៅក្រោមការទទួលខុសត្រូវរបស់អាជ្ញាធរកម្ពុជាគ្រប់គ្រងសកម្មភាពកំចាត់មីន និងសង្គ្រោះជនពិការដោយសារមីន។

## ព័ត៌មានស្តីពីគ្រោះថ្នាក់ និងជនរងគ្រោះដោយសារមីន និងស.ផ.ស.

### 1- ជនរងគ្រោះពីខែមករា ឆ្នាំ១៩៧៩ ដល់ខែមិថុនា ឆ្នាំ២០១៩

ចាប់ពីខែមករា ឆ្នាំ១៩៧៩ ដល់ខែមិថុនា ឆ្នាំ២០១៩ មានជនរងគ្រោះដោយសារមីន និងស.ផ.ស. ចំនួន ៦៤.៨៤០នាក់ ដែលបានកត់ត្រាដោយមន្ត្រី-បុគ្គលិកប្រមូលទិន្នន័យរបស់ការិយាល័យ CMVIS ក្នុងចំណោមជនរងគ្រោះចំនួន ៦៤.៨៤០នាក់ រួមមាន៖

- ជនរងគ្រោះដោយសារមីន ៥១.០៩១នាក់(៧៩%) និងស.ផ.ស. ១៣.៧៤៩នាក់(២១%)។
- ជនរងគ្រោះស្លាប់ ១៩.៧៧៩នាក់(៣១%) របួស ៣៦.០១៦នាក់(៥៥%) និងពិការអវៈយវៈ ៩.០៤៥នាក់(១៤%)។
- ជនរងគ្រោះជាបុរស ៥២.៥៣៦នាក់(៨១%) ក្មេងប្រុសអាយុក្រោម១៨ឆ្នាំ ៦.០៦៤នាក់(៩%) ស្ត្រី ៤.៧៨៧នាក់(៨%) ក្មេងស្រីអាយុក្រោម១៨ឆ្នាំ ១.៣៩០នាក់(២%) និងមិនស្គាល់អត្តសញ្ញាណ ៦៣នាក់(0%)។

### 2- ឧប្បត្តិហេតុគ្រោះថ្នាក់ពីខែមករា ដល់ខែមិថុនា ឆ្នាំ២០១៩

ចាប់ពីខែមករា ដល់ខែមិថុនា ឆ្នាំ២០១៩ មានឧប្បត្តិហេតុគ្រោះថ្នាក់មីន និងស.ផ.ស. ៤១ករណី តួលេខនេះបង្ហាញពីការកើនឡើង ៩៥% បើប្រៀបធៀបជាមួយនឹងរយៈពេលដូចគ្នានៅក្នុងឆ្នាំ២០១៨ ដែលមានឧប្បត្តិហេតុគ្រោះថ្នាក់មីន និងស.ផ.ស. ២១ករណី។

ក្នុងចំណោមឧប្បត្តិហេតុគ្រោះថ្នាក់ដោយសារមីន និងស.ផ.ស. ៤១ករណី ចាប់ពីខែមករា ដល់ខែ មិថុនា ឆ្នាំ២០១៩ រួមមាន៖ ឧប្បត្តិហេតុដោយសារមីន ១៧ករណី(៤១%) និងស.ផ.ស. ២៤ករណី (៥៩%)។

### 3- ជនរងគ្រោះពីខែមករា ដល់ខែមិថុនា ឆ្នាំ២០១៩

តួលេខបណ្តោះអាសន្ន ស្តីពីជនរងគ្រោះដោយសារមីន និងស.ផ.ស. ពីខែមករា ដល់ខែមិថុនា ឆ្នាំ២០១៩ មាន ៦២នាក់។ តួលេខនេះបង្ហាញពីការកើនឡើង ១០០% ប្រៀបធៀបជាមួយនឹងរយៈពេលដូចគ្នានៅក្នុងឆ្នាំ២០១៨ ដែលមានជនរងគ្រោះដោយសារមីន និងស.ផ.ស. ៣១នាក់។

ក្នុងចំណោមជនរងគ្រោះ ៦២នាក់ រួមមាន៖

- ជនរងគ្រោះដោយសារមីន ១៦នាក់(២៦%) និងស.ផ.ស. ៤៦នាក់(៧៤%)
- ជនរងគ្រោះស្លាប់ ១១នាក់(១៨%) របួស ៣៩នាក់(៦៣%) និងពិការអវៈយវៈ ១២នាក់(២០%)
- ជនរងគ្រោះជាបុរស ៤៣នាក់(៦៩%) ក្មេងប្រុសអាយុក្រោម១៨ឆ្នាំ ១៣នាក់(២១%) និងស្ត្រី ៦ នាក់(១០%)។

## 4- ឧប្បត្តិហេតុគ្រោះថ្នាក់ក្នុងខែមិថុនា ឆ្នាំ២០១៩

នៅខែមិថុនា ឆ្នាំ២០១៩ មានឧប្បត្តិហេតុគ្រោះថ្នាក់ដោយសារមីន និងស.ផ.ស. ១១ករណី ក្នុងនោះ ឧប្បត្តិហេតុដោយសារមីន ៦ករណី(៥៥%) និងឧប្បត្តិហេតុដោយសារស.ផ.ស. ៥ករណី(៤៥%) ដែលបានកើតឡើងនៅខេត្តប៉ៃលិន ខេត្តព្រះវិហារ ខេត្តឧត្តរមានជ័យ ខេត្តបាត់ដំបង ខេត្តកណ្តាល ខេត្តកំពង់ចាម និងខេត្តស្វាយរៀង (មន្ត្រី-បុគ្គលិកប្រមូលទិន្នន័យការិយាល័យ CMVIS ប្រមូលព័ត៌មានបឋមអំពីឧប្បត្តិហេតុគ្រោះថ្នាក់ដោយសារមីន និងស.ផ.ស. តាមរយៈការសម្ភាសជាមួយ អាជ្ញាធរមូលដ្ឋាន ភ្នាក់ងារសកម្មភាពមីន គ្រួសារសាច់ញាតជនរងគ្រោះ ឬជនរងគ្រោះផ្ទាល់)។ ឧប្បត្តិហេតុគ្រោះថ្នាក់ដោយសារមីន និងស.ផ.ស. ក្នុងខែមិថុនា ឆ្នាំ២០១៩ បានកើនឡើង ១០០០% បើប្រៀបធៀបជាមួយនឹងខែមិថុនា ឆ្នាំ២០១៨ ដែលមានឧប្បត្តិហេតុគ្រោះថ្នាក់ដោយសារមីន និងស.ផ.ស. ១ករណី។

- ប្រភេទយុទ្ធភ័ណ្ឌគ្រឿងផ្ទុះ




- ព័ត៌មានអំពីតំបន់គ្រោះថ្នាក់ដោយសារមីន និងស.ផ.ស. ខែមិថុនា ឆ្នាំ២០១៩



## 5- ជនរងគ្រោះក្នុងខែមិថុនា ឆ្នាំ២០១៩

នៅខែមិថុនា ឆ្នាំ២០១៩ មានជនរងគ្រោះដោយសារមីន និងស.ផ.ស. ១២នាក់ តួលេខនេះបង្ហាញថា បានកើនឡើង ១១០០% បើប្រៀបធៀបជាមួយនឹងខែមិថុនា ឆ្នាំ២០១៨ ដែលមានជនរងគ្រោះ ១នាក់។

ក្នុងចំណោមជនរងគ្រោះ ១២នាក់ ក្នុងខែមិថុនា ឆ្នាំ២០១៩ រួមមាន៖

- ជនរងគ្រោះដោយសារមីន ៤នាក់(៣៣%) និងស.ផ.ស. ៨នាក់(៦៧%)
- ជនរងគ្រោះរបួស ៧នាក់(៥៨%) ពិការ ២នាក់(១៧%) និងស្លាប់ ៣នាក់(២៥%)
- ជនរងគ្រោះជាបុរស ៥នាក់(៤២%) ក្មេងប្រុសអាយុក្រោម១៨ឆ្នាំ ៤នាក់(៣៣%) និងជាស្ត្រី ៣នាក់(២៥%)។
- សកម្មភាពនៅពេលគ្រោះថ្នាក់ដោយសារមីន និងស.ផ.ស. ដែលបណ្តាលឲ្យជនរងគ្រោះ បានស្លាប់ របួស និងពិការ មានដូចជា៖ សកម្មភាពលេង ឬច្នៃគ្រាប់ ៤នាក់(៣៣%) សកម្មភាពធ្វើកសិកម្ម ២នាក់(១៧%) សកម្មភាពឈរ/អង្គុយក្បែរកន្លែងរងគ្រោះ ២នាក់(១៧%) សកម្មភាពកាប់ឈើ ២នាក់(១៧%) សកម្មភាពដុតភ្លើង ១នាក់(៨%) និងសកម្មភាពសម្អាតដីធ្វើកសិកម្ម ១នាក់(៨%)។

សកម្មភាពនៅពេលគ្រោះថ្នាក់របស់ជនរងគ្រោះដោយសារមីន/ស.ផ.ស. ក្នុងខែមិថុនា ឆ្នាំ២០១៩




## 6- ផលប៉ះពាល់នៃតំបន់គ្រោះថ្នាក់ពីខែមករា ឆ្នាំ២០១៨ ដល់ខែមិថុនា ឆ្នាំ២០១៩(ជនរងគ្រោះ ១២០នាក់)

- ខេត្តចំនួន ៥ ដែលទទួលរងផលប៉ះពាល់ខ្លាំងបំផុតមានជនរងគ្រោះ ៥៨% នៃជនរងគ្រោះសរុប
- ស្រុកចំនួន ១០ ដែលទទួលរងផលប៉ះពាល់ខ្លាំងបំផុតមានជនរងគ្រោះ ៥៨% នៃជនរងគ្រោះសរុប
- ឃុំចំនួន ១០ ដែលទទួលរងផលប៉ះពាល់ខ្លាំងបំផុតមានជនរងគ្រោះ ៤២% នៃជនរងគ្រោះសរុប។

*សូមអានព័ត៌មានលម្អិត នៅទំព័រទី ៨*

# ប្រព័ន្ធព័ត៌មានជនរងគ្រោះដោយសារមីន និងសំណល់ជាតិផ្ទុះពីសង្គ្រាម
## ទីតាំងគ្រោះថ្នាក់ដោយសារមីន និងសំណល់ជាតិផ្ទុះពីសង្គ្រាម នៅខែមិថុនា ឆ្នាំ២០១៩
## ឧប្បត្តិហេតុ ១១ករណី ជនរងគ្រោះ ១២នាក់




ព័ត៌មានលម្អិតទាក់ទងនឹងទិន្នន័យគ្រោះថ្នាក់មីន និងស.ផ.ស. សូមទំនាក់ទំនងមកការិយាល័យ CMVIS តាមរយៈអ៊ីម៉ែល: ketya@cmaa.gov.kh

ប្រព័ន្ធពត៌មានជនរងគ្រោះដោយសារមីន នៅ កម្ពុជា

# របាយការណ៍ជនរងគ្រោះដោយសារមីន និងសំណល់ជាតិផ្ទុះពីសង្គ្រាមពីខែមករា ឆ្នាំ2016 ដល់ខែមិថុនា ឆ្នាំ2019

| | ជនរងគ្រោះតាមខែ | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|
| ឆ្នាំ/ខែ | មករា | កុម្ភៈ | មីនា | មេសា | ឧសភា | មិថុនា | កក្កដា | សីហា | កញ្ញា | តុលា | វិច្ឆិកា | ធ្នូ | សរុប |
| **2016** | **8** | **10** | **7** | **8** | **11** | **7** | **8** | **4** | **6** | **6** | **2** | **6** | **83** |
| *ការបូកបណ្តាក់ ឆ្នាំ2016* | *8* | *18* | *25* | *33* | *44* | *51* | *59* | *63* | *69* | *75* | *77* | *83* | |
| **2017** | **8** | **11** | **0** | **7** | **3** | **3** | **2** | **5** | **4** | **5** | **3** | **7** | **58** |
| *ការបូកបណ្តាក់ ឆ្នាំ2017* | 8 | 19 | 19 | 26 | 29 | 32 | 34 | 39 | 43 | 48 | 51 | 58 | |
| *ការប្រែប្រួលភាគរយ 2016 ធៀប 2017* | 0.0 | 5.6 | -24.0 | -21.2 | -34.1 | -37.3 | -42.4 | -38.1 | -37.7 | -36.0 | -33.8 | -30.1 | |
| **2018** | **5** | **7** | **5** | **7** | **6** | **1** | **1** | **11** | **6** | **1** | **4** | **4** | **58** |
| *ការប្រែប្រួលតួលេខតាមខែធៀប 2017* | -3 | -4 | 5 | 0 | 3 | -2 | -1 | 6 | 2 | -4 | 1 | -3 | |
| *ការប្រែប្រួលភាគរយតាមខែធៀប 2017* | -38 | -36 | 100 | 0 | 100 | -67 | -50 | 120 | 50 | -80 | 33 | -43 | |
| *ការបូកបណ្តាក់ ឆ្នាំ2018* | ***5*** | ***12*** | ***17*** | ***24*** | ***30*** | ***31*** | ***32*** | ***43*** | ***49*** | ***50*** | ***54*** | ***58*** | |
| *ការប្រែប្រួលភាគរយ 2017 ធៀប 2018* | -37.5 | -36.8 | -10.5 | -7.7 | 3.4 | -3.1 | -5.9 | 10.3 | 14.0 | 4.2 | 5.9 | 0.0 | |
| **2019** | **18** | **4** | **22** | **3** | **3** | **12** | | | | | | | **62** |
| *ការប្រែប្រួលតួលេខតាមខែធៀប 2018* | 13 | -3 | 17 | -4 | -3 | 11 | | | | | | | |
| *ការប្រែប្រួលភាគរយតាមខែធៀប 2018* | 260 | -43 | 340 | -57 | -50 | 1100 | | | | | | | |
| *ការបូកបណ្តាក់ ឆ្នាំ2019* | ***18*** | 22 | ***44*** | ***47*** | ***50*** | ***62*** | | | | | | | |
| *ការប្រែប្រួលភាគរយ 2018 ធៀប 2019* | 260 | 83.3 | 158.8 | 95.8 | 66.7 | 100 | | | | | | | |

ចំណាំ: តួលេខជនរងគ្រោះសម្រាប់ខែបន្តបន្ទាប់ទៀតនឹងស្រាវជ្រាវឲ្យទាន់ពេលវេលា ដែលជាផ្នែកមួយនៃដំណើរការប្រមូលទិន្នន័យ



# ជនរងគ្រោះដោយសារមីន និងសំណល់ជាតិផ្ទុះពីសង្គ្រាម ចាប់ពីខែមករា ឆ្នាំ2018 ដល់ខែមិថុនា ឆ្នាំ2019

## រាជធានីខេត្តត្រូវបានតំរៀបតាមលំដាប់ចុះនៃផលបូកសរុបជនរងគ្រោះដោយសារមីន និងសំណល់ជាតិផ្ទុះពីសង្គ្រាមក្នុងឆ្នាំ2018 និងឆ្នាំ2019

| ឈ្មោះខេត្ត | មករា18 | កុម្ភៈ18 | មីនា18 | មេសា18 | ឧសភា18 | មិថុនា18 | កក្កដា18 | សីហា18 | កញ្ញា18 | តុលា18 | វិច្ឆិកា18 | ធ្នូ18 | សរុប2018 | មករា19 | កុម្ភៈ19 | មីនា19 | មេសា19 | ឧសភា19 | មិថុនា19 | កក្កដា19 | សីហា19 | កញ្ញា19 | តុលា19 | វិច្ឆិកា19 | ធ្នូ19 | សរុប2019 | សរុប 2018-2019 | ការបូកបណ្តាក់លើសរុប | ភាគរយនៃសរុប | ការបូកបណ្តាក់លើភាគរយសរុប |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | ចំនួន | ចំនួន | ចំនួន | ចំនួន | ចំនួន | ចំនួន | ចំនួន | ចំនួន | ចំនួន | ចំនួន | ចំនួន | ចំនួន | **ចំនួន** | ចំនួន | ចំនួន | ចំនួន | ចំនួន | ចំនួន | ចំនួន | ចំនួន | ចំនួន | ចំនួន | ចំនួន | ចំនួន | ចំនួន | **ចំនួន** | | | | |
| បាត់ដំបង | 1 | 0 | 0 | 4 | 0 | 0 | 0 | 0 | 0 | 0 | 0 | 3 | **8** | 2 | 2 | 2 | 1 | 0 | 1 | 0 | 0 | 0 | 0 | 0 | 0 | **8** | **16** | 16 | 13.3 | 13 |
| ត្បូងឃ្មុំ | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 1 | 0 | **1** | 10 | 0 | 4 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | **14** | **15** | 31 | 12.5 | 26 |
| ព្រះវិហារ | 0 | 0 | 0 | 0 | 1 | 1 | 0 | 1 | 4 | 1 | 0 | 0 | **8** | 2 | 0 | 0 | 2 | 0 | 2 | 0 | 0 | 0 | 0 | 0 | 0 | **6** | **14** | 45 | 11.7 | 38 |
| រតនៈគិរី | 0 | 2 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | **2** | 1 | 2 | 8 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | **11** | **13** | 58 | 10.8 | 48 |
| កំពង់ស្ពឺ | 2 | 0 | 5 | 0 | 0 | 0 | 0 | 4 | 0 | 0 | 0 | 0 | **11** | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | **0** | **11** | 69 | 9.2 | 58 |
| ឧត្តរមានជ័យ | 0 | 0 | 0 | 0 | 0 | 0 | 1 | 2 | 0 | 0 | 2 | 0 | **5** | 0 | 0 | 3 | 0 | 0 | 1 | 0 | 0 | 0 | 0 | 0 | 0 | **4** | **9** | 78 | 7.5 | 65 |
| បន្ទាយមានជ័យ | 0 | 0 | 0 | 0 | 2 | 0 | 0 | 1 | 0 | 0 | 0 | 0 | **3** | 2 | 0 | 2 | 0 | 1 | 0 | 0 | 0 | 0 | 0 | 0 | 0 | **5** | **8** | 86 | 6.7 | 72 |
| កណ្តាល | 0 | 0 | 0 | 2 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | **2** | 0 | 0 | 0 | 0 | 1 | 2 | 0 | 0 | 0 | 0 | 0 | 0 | **3** | **5** | 91 | 4.2 | 76 |
| ក្រចេះ | 0 | 0 | 0 | 1 | 0 | 0 | 0 | 0 | 2 | 0 | 0 | 0 | **3** | 1 | 0 | 1 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | **2** | **5** | 96 | 4.2 | 80 |
| កំពង់ចាម | 0 | 2 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | **2** | 0 | 0 | 0 | 0 | 0 | 2 | 0 | 0 | 0 | 0 | 0 | 0 | **2** | **4** | 100 | 3.3 | 83 |
| ពោធិ៍សាត់ | 1 | 0 | 0 | 0 | 0 | 0 | 0 | 1 | 0 | 0 | 1 | 0 | **3** | 0 | 0 | 1 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | **1** | **4** | 104 | 3.3 | 87 |
| សៀមរាប | 0 | 1 | 0 | 0 | 2 | 0 | 0 | 0 | 0 | 0 | 0 | 0 | **3** | 0 | 0 | 0 | 0 | 1 | 0 | 0 | 0 | 0 | 0 | 0 | 0 | **1** | **4** | 108 | 3.3 | 90 |
| ប៉ៃលិន | 1 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | **1** | 0 | 0 | 0 | 0 | 0 | 2 | 0 | 0 | 0 | 0 | 0 | 0 | **2** | **3** | 111 | 2.5 | 93 |
| ស្វាយរៀង | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | **0** | 0 | 0 | 0 | 0 | 0 | 2 | 0 | 0 | 0 | 0 | 0 | 0 | **2** | **2** | 113 | 1.7 | 94 |
| កំពង់ឆ្នាំង | 0 | 0 | 0 | 0 | 0 | 0 | 0 | 2 | 0 | 0 | 0 | 0 | **2** | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | **0** | **2** | 115 | 1.7 | 96 |
| កោះកុង | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 1 | **1** | 0 | 0 | 1 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | **1** | **2** | 117 | 1.7 | 98 |
| មណ្ឌលគិរី | 0 | 2 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | **2** | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | **0** | **2** | 119 | 1.7 | 99 |
| ភ្នំពេញ | 0 | 0 | 0 | 0 | 1 | 0 | 0 | 0 | 0 | 0 | 0 | 0 | **1** | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | **0** | **1** | 120 | 0.8 | 100 |
| កំពត | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | **0** | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | **0** | **0** | 120 | 0 | 100 |
| កំពង់ធំ | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | **0** | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | **0** | **0** | 120 | 0 | 100 |
| ព្រះសីហនុ | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | **0** | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | **0** | **0** | 120 | 0 | 100 |
| ស្ទឹងត្រែង | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | **0** | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | **0** | **0** | 120 | 0 | 100 |
| តាកែវ | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | **0** | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | **0** | **0** | 120 | 0 | 100 |
| កែប | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | **0** | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | **0** | **0** | 120 | 0 | 100 |
| ព្រៃវែង | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | **0** | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | **0** | **0** | 120 | 0 | 100 |
| សរុប | 5 | 7 | 5 | 7 | 6 | 1 | 1 | 11 | 6 | 1 | 4 | 4 | **58** | 18 | 4 | 22 | 3 | 3 | 12 | 0 | 0 | 0 | 0 | 0 | 0 | **62** | **120** | | | |

## ក្រាហ្វិចជនរងគ្រោះដោយសារមីន និងសំណល់ជាតិផ្ទុះពីសង្គ្រាមតាមខេត្តនីមួយៗ



## ខេត្តចំនួន 5 ទទួលរងឥទ្ធិពលខ្លាំងជាងគេ ដោយសារមីន និងសំណល់ជាតិផ្ទុះពីសង្គ្រាម

ត្រូវបានតម្រៀបតាមលំដាប់ចុះ នៃផលបូកសរុបជនរងគ្រោះ

ពីខែមករា2018 ដល់ខែមិថុនា2019

| លំដាប់ | ខេត្ត | អ្នករងគ្រោះ មីន | អ្នករងគ្រោះ សំណល់ជាតិផ្ទុះពីសង្គ្រាម | ផលបូកសរុប អ្នករងគ្រោះ | ការបូកបណ្តាក់ លើផលបូកសរុប |
|---|---|---|---|---|---|
| 1 | បាត់ដំបង | 6 | 10 | **16** | 16 |
| 2 | ត្បូងឃ្មុំ | 0 | 15 | **15** | 31 |
| 3 | ព្រះវិហារ | 8 | 6 | **14** | 45 |
| 4 | រតនៈគិរី | 0 | 13 | **13** | 58 |
| 5 | កំពង់ស្ពឺ | 0 | 11 | **11** | 69 |

## ស្រុកចំនួន 10 ទទួលរងឥទ្ធិពលខ្លាំងជាងគេ ដោយសារមីន និងសំណល់ជាតិផ្ទុះពីសង្គ្រាម

ត្រូវបានតម្រៀបតាមលំដាប់ចុះ នៃផលបូកសរុបជនរងគ្រោះ

ពីខែមករា2018 ដល់ខែមិថុនា2019

| លំដាប់ | ខេត្ត | ស្រុក | អ្នករងគ្រោះ មីន | អ្នករងគ្រោះ សំណល់ជាតិផ្ទុះពីសង្គ្រាម | ផលបូកសរុប អ្នករងគ្រោះ | ការបូកបណ្តាក់ លើផលបូកសរុប |
|---|---|---|---|---|---|---|
| 1 | ត្បូងឃ្មុំ | ត្បូងឃ្មុំ | 0 | 12 | **12** | 12 |
| 2 | ព្រះវិហារ | ជាំក្សាន្ត | 7 | 5 | **12** | 24 |
| 3 | កំពង់ស្ពឺ | ភ្នំស្រួច | 0 | 11 | **11** | 35 |
| 4 | រតនៈគិរី | អូរយ៉ាដាវ | 0 | 8 | **8** | 43 |
| 5 | បាត់ដំបង | សំឡូត | 4 | 4 | **8** | 51 |
| 6 | រតនៈគិរី | តាវែង | 0 | 5 | **5** | 56 |
| 7 | ក្រចេះ | ស្នួល | 0 | 4 | **4** | 60 |
| 8 | ឧត្តរមានជ័យ | ត្រពាំងប្រាសាទ | 4 | 0 | **4** | 64 |
| 9 | បាត់ដំបង | កំរៀង | 0 | 3 | **3** | 67 |
| 10 | បាត់ដំបង | រតនៈមណ្ឌល | 2 | 1 | **3** | 70 |

## ឃុំចំនួន 10 ទទួលរងឥទ្ធិពលខ្លាំងជាងគេ ដោយសារមីន និងសំណល់ជាតិផ្ទុះពីសង្គ្រាម

ត្រូវបានតម្រៀបតាមលំដាប់ចុះ នៃផលបូកសរុបជនរងគ្រោះ

ពីខែមករា2018 ដល់ខែមិថុនា2019

| លំដាប់ | ឃុំ | ស្រុក | ខេត្ត | អ្នករងគ្រោះ មីន | អ្នករងគ្រោះ សំណល់ជាតិផ្ទុះពីសង្គ្រាម | ផលបូកសរុប អ្នករងគ្រោះ | ការបូកបណ្តាក់ លើផលបូកសរុប |
|---|---|---|---|---|---|---|---|
| 1 | ជីរោទ៍១ | ត្បូងឃ្មុំ | ត្បូងឃ្មុំ | 0 | 10 | **10** | 10 |
| 2 | មហាសាំង | ភ្នំស្រួច | កំពង់ស្ពឺ | 0 | 9 | **9** | 19 |
| 3 | យ៉ាទុង | អូរយ៉ាដាវ | រតនៈគិរី | 0 | 5 | **5** | 24 |
| 4 | តាវែងក្រោម | តាវែង | រតនៈគិរី | 0 | 5 | **5** | 29 |
| 5 | មរកត | ជាំក្សាន្ត | ព្រះវិហារ | 4 | 0 | **4** | 33 |
| 6 | ជាំក្សាន្ត | ជាំក្សាន្ត | ព្រះវិហារ | 3 | 1 | **4** | 37 |
| 7 | កំពង់ល្ពៅ | សំឡូត | បាត់ដំបង | 0 | 4 | **4** | 41 |
| 8 | អូរដា | កំរៀង | បាត់ដំបង | 0 | 3 | **3** | 44 |
| 9 | តាតោក | សំឡូត | បាត់ដំបង | 3 | 0 | **3** | 47 |
| 10 | កូនគ្រៀល | សំរោង | ឧត្តរមានជ័យ | 3 | 0 | **3** | 50 |

ប្រព័ន្ធព័ត៌មានជនរងគ្រោះដោយសារមីន នៅ កម្ពុជា

# ការឆ្លុះបញ្ចាំងទូទៅលើជនរងគ្រោះដោយសារមីន និងសំណល់ជាតិផ្ទុះពីសង្គ្រាម

អំឡុងពេលៈ មករា2018 - មិថុនា2019

ចំនួនសរុបនៃជនរងគ្រោះក្នុងអំឡុងពេលរាយការណ៍ៈ 120










## ការឆ្លុះបញ្ចាំងទូទៅលើករណីរងគ្រោះដោយសារមីន និងសំណល់ជាតិផ្ទុះពីសង្គ្រាម












អំឡុងពេល: ខែមករា 2018 - ខែមិថុនា 2019

ចំនួនសរុបនៃជនរងគ្រោះ ក្នុងអំឡុងពេលរាយការណ៍: 120

## សកម្មភាពដែលបណ្តាលឲ្យគ្រោះថ្នាក់បែងចែកទៅតាមប្រភេទ:

| បុរស | ស្ត្រី | ក្មេង | សរុប |
|---|---|---|---|
| 79 | 12 | 29 | 120 |




## ឧប្បត្តិហេតុគ្រោះថ្នាក់ដោយសារមីន និងសំណល់ជាតិផ្ទុះពីសង្គ្រាមតាមលក្ខណៈភូមិសាស្ត្រដី

### សកម្មភាពដែលបណ្តាលឲ្យផ្ទុះមីន




### សកម្មភាពដែលបណ្តាលឲ្យផ្ទុះសំណល់ជាតិផ្ទុះពីសង្គ្រាម




### លក្ខណៈភូមិសាស្ត្រដីដែលបណ្តាលឲ្យផ្ទុះមីន




### លក្ខណៈភូមិសាស្ត្រដីដែលបណ្តាលឲ្យផ្ទុះសំណល់ជាតិផ្ទុះពីសង្គ្រាម

